**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សូមគោរពជូន
# សម្តេចវិបុលសេនាភក្តី សាយ ឈុំ
# ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

***សម្តេចប្រធាន ជាទីគោរពដ៏ខ្ពង់ខ្ពស់***

ខ្ញុំបាទ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងឧស្សាហកម្ម និងសិប្បកម្មគ្រប់លំដាប់ថ្នាក់ សូមគោរពផ្ញើជូន **សម្តេច និងលោកជំទាវ** ព្រមទាំងក្រុមគ្រួសារទាំងអស់នូវសេចក្តីអំណរសាទរយ៉ាងក្លៀវក្លាកក់ក្តៅបំផុត ប្រកបដោយមនោសញ្ចេតនារំភើប រីករាយក្រៃលែង ក្នុងឱកាសដែលព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា **ប្រោសព្រះរាជទានគោរមងារ សម្តេចវិបុលសេនាភក្តី សាយ ឈុំ** តាមព្រះរាជក្រឹត្យលេខ នស/រកត/០៦១៥/៦៣៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៥។

គោរមងារដែល **សម្តេច** ទទួលបាននាពេលនេះ គឺពិតជាស័ក្តិសមបំផុតចំពោះវីរភាពដ៏ឧត្តុងឧត្តមថ្លៃថ្លារបស់ **សម្តេច** ដែលជាអ្នកដឹកនាំដ៏ឆ្នើមមួយរូបរបស់ប្រជាជាតិខ្មែរយើង បានយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី ពុះពារជំនះឧបសគ្គគ្រប់បែបយ៉ាង និងគ្រប់កាលៈទេសៈ ចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការស្តារ និងអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ សម្រេចបាននូវសុខសន្តិភាព ឯកភាពជាតិ ស្ថិរភាពសង្គម ស្ថិរភាពនយោបាយ ពង្រឹងនីតិរដ្ឋ រក្សាការពារឯករាជ្យជាតិ បូរណភាពទឹកដី ប្រកបដោយទឹកចិត្តស្នាមីភក្តិជានិច្ចចំពោះជាតិ សាសនា ព្រះមហាក្សត្រ។

យើងខ្ញុំទាំងអស់គ្នា មានជំនឿយ៉ាងមុតមាំថា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេច** ស្ថាប័នព្រឹទ្ធសភានឹងបន្តទទួលបានជោគជ័យថ្មីៗថែមទៀត សម្រេចបាននូវសមិទ្ធផលជាផ្លែផ្កាជាឧត្តមប្រយោជន៍របស់ជាតិ មាតុភូមិស្របទៅតាមបំណងប្រាថ្នាដ៏ថ្លៃថ្លារបស់ប្រជាជនកម្ពុជា ទាំងនៅក្នុង និងក្រៅប្រទេស។

ឆ្លៀតក្នុងឱកាសដ៏ឧត្តុងឧត្តមនេះ ខ្ញុំបាទ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅជូនចំពោះ **សម្តេច** និងសូមលើកហត្ថប្រណមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាភពផែនដី និងគុណបុណ្យព្រះត្រៃរតន័យ សូមមេត្តាប្រោសព្រំ និងប្រសិទ្ធពរជ័យជូនចំពោះ **សម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភា និងលោកជំទាវ** ព្រមទាំងក្រុមគ្រួសារជាទីស្រឡាញ់ទាំងអស់ សូមជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ និងភក្តីភាពដ៏ជ្រាលជ្រៅពីខ្ញុំបាទ យើងខ្ញុំទាំងអស់គ្នា។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០១៥

**តំណាងថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**ទេសរដ្ឋមន្ត្រី**

**ចម ប្រសិទ្ធ**